ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
'រ.ទ.ស.ភ'
លេខ ..២១៥..ស.ន.ណ

ភ្នំពេញ, ថ្ងៃទី១២ ខែ កញ្ញា ឆ្នាំ ២០១៧

# សេចក្តីជូនដំណឹង
## ស្តីពីការទូទាត់សងប្រាក់ថ្លៃទឹកលម្អៀង

យោងសេចក្តីជូនដំណឹងរបស់ក្រសួងឧស្សាហកម្មនិងសិប្បកម្ម លេខ ២០៤៩ឱ.សMIH/២០១៧ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញមានកិត្តិយសសូមគោរពទូលថ្វាយ និងជម្រាបបញ្ជាក់ជាថ្មីម្តងទៀតជូន សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ដែលជាអតិថិជនប្រើប្រាស់ទឹករបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញទូទាំងរាជធានីភ្នំពេញ និងទីក្រុងតាខ្មៅ មេត្តាជ្រាបថា រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ បានធ្វើការកែតម្រូវការគណនាតម្លៃទឹកត្រឡប់ទៅតាមរបៀបគណនាចាស់ហើយ និងកំពុងធ្វើការទូទាត់សងនូវប្រាក់ថ្លៃទឹកលម្អៀងជូនអតិថិជនវិញ តាម២ជម្រើស ដូចខាងក្រោម ៖

**ជម្រើសទី១** : អតិថិជនអាចអញ្ជើញមកទទួលសាច់ប្រាក់នោះដោយផ្ទាល់ នៅបញ្ជរបេឡាទទួលប្រាក់ណាមួយរបស់រដ្ឋាករ ទឹកស្វយ័តក្រុងភ្នំពេញ រៀងរាល់ថ្ងៃធ្វើការពីម៉ោង០៨:០០ ដល់ម៉ោង១៦:០០។

**ជម្រើសទី២** : ក្នុងករណីអតិថិជនមិនបានមកទទួលទឹកប្រាក់លម្អៀង រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញនឹងកាត់កងទឹកប្រាក់លម្អៀងនេះ ជាមួយថ្លៃប្រើប្រាស់ទឹកនៅវិក្កយបត្របន្ទាប់។

ក្នុងករណី សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី មានសំណួរ ឬចម្ងល់ពាក់ព័ន្ធនឹងករណីនេះ សូមមេត្តាទាក់ទងតាមរយៈ ៖

១- លេខទូរស័ព្ទ : ០២៣ ៤៣០ ៥៤១ រៀងរាល់ថ្ងៃធ្វើការពីម៉ោង០៨:០០ ដល់ម៉ោង១៦:០០ ឬ

២- ភ្នាក់ងារអានលេខនិងចែកវិក្កយបត្រទឹក ដែលបំពេញការងារនៅទីតាំងផ្ទាល់។

អាស្រ័យហេតុនេះ សូមសម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី មេត្តាជ្រាប ដោយអនុគ្រោះ។

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

អាសយដ្ឋាន: លេខ៤៥ ផ្លូវ ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ទូរស័ព្ទ: ៨៥៥(២៣) ៧២៤ ០៤៦ Email: admin@ppwsa.com.kh